ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

# សារលិខិត

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុងឱកាសបើកបវេសនកាលឆ្នាំសិក្សា ២០១៦-២០១៧

## រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦

*- សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*- សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី*

*- លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ក្មួយៗសិស្សានុសិស្ស និងបងប្អូនជនរួមជាតិទាំងអស់ ជាទីស្នេហា !*

សម្រាប់ **ទិវាទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៦** ដ៏មានសារៈសំខាន់នេះ ខ្ញុំព្រះករុណាខ្ញុំមានសេចក្តីរីករាយចូលរួមអបអរសាទរជាមួយបងប្អូនជនរួមជាតិ លោកគ្រូអ្នកគ្រូ បុគ្គលិកសិក្សា ព្រមទាំងក្មួយៗសិស្សានុសិស្សទាំងអស់ គ្រប់ភូមិសិក្សា ទាំងសិស្សថ្មី ទាំងសិស្សចាស់ ដែលបាននិងកំពុងរៀបចំខ្លួន សម្តែងការអបអរសាទរនឹងទិវាបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០១៦-២០១៧ នៅទូទាំងព្រះរាជាណាចក្រកម្ពុជាយើង ។ ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ នេះ គឺជាការបើកទំព័រឆ្នាំសិក្សាថ្មី សម្រាប់សិស្សានុសិស្ស- និស្សិត ដែលជាកុលបុត្រកុលធីតាជាទីស្រឡាញ់របស់យើងគ្រប់ៗគ្នាបានបន្តការសិក្សាទៅថ្នាក់ខ្ពស់បន្តទៀត និងជាថ្ងៃផ្តើមជីវិតសិក្សាដំបូងរបស់កុមារដែលទើបនឹងដល់អាយុត្រូវចូលសាលារៀន ។

ក្នុងទិវាដ៏ឧឡារិកនេះ ខ្ញុំព្រះករុណាខ្ញុំសូមសម្តែងនូវមនោសញ្ចេតនារីករាយថ្លែងនូវសារលិខិតជូនជនរួមជាតិជាទីស្នេហា នូវឆន្ទៈ និងបុព្វហេតុយកចិត្តទុកដាក់លើកកម្ពស់វិស័យអប់រំ ជាពិសេសការជំរុញការកសាងមូលធនមនុស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព ។ យើងទាំងអស់គ្នាបានដឹងហើយថា ការសិក្សារៀនសូត្រមិនត្រឹមតែត្រូវអនុវត្តបន្តពេញមួយជីវិតប៉ុណ្ណោះទេ ប៉ុន្តែគឺជាការងារមួយតម្រូវឱ្យមានការលើកកម្ពស់និងអភិវឌ្ឍគ្មានទីបញ្ចប់ ដើម្បីផលិតនូវធនធានមនុស្សប្រកបដោយគុណភាព មានសក្តានុពលសម្រាប់ការអភិវឌ្ឍសង្គមជាតិឱ្យមានការរីកចម្រើន ភាពសុខដុម និងចិរភាពទៀតផង ។ ទន្ទឹមនេះ ការអប់រំត្រូវតែឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងមានដំណើរការឆ្លើយតបទៅនឹងបរិការណ៍នៃសកលភាវូបនីយកម្ម ។

ស្របជាមួយនេះ ការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចនិងបច្ចេកវិទ្យាព័ត៌មានបាននិងកំពុងទទួលនូវឧត្តមភាពយ៉ាងខ្លាំង ។ ប៉ុន្តែទោះបីជាបច្ចេកវិទ្យាមានការវិវឌ្ឍយ៉ាងខ្លាំងក៏ដោយ ក៏មិនអាចទៅជំនួសឱ្យធនធានមនុស្សបានឡើយ ។ ក្នុងន័យនេះ ពិតណាស់ថាសង្គមជាតិមួយអាចរីកចម្រើនបាន មិនប្រាកដថាសង្គមជាតិនោះត្រូវសម្បូណ៌ទៅដោយធនធានធម្មជាតិនោះទេ តែផ្ទុយមកវិញ សង្គមជាតិដែលសម្បូណ៌ដោយធនធានមនុស្សប្រកបដោយសក្តានុពលអាចប្រែក្លាយសង្គមជាតិរបស់ខ្លួនឱ្យមានការអភិវឌ្ឍលឿនលឿនបានយ៉ាងរឹងមាំ ។

ក្នុងស្មារតីនេះ ខ្ញុំនៅតែយល់ថា ***«ការអប់រំល្អ គឺជាកូនសោសម្រាប់ដោះស្រាយនូវរាល់បញ្ហាសង្គម និងសេដ្ឋកិច្ចជាតិ»*** ។ ជាក់ស្តែង ក្នុងយុគសម័យ ***សេដ្ឋកិច្ចពុទ្ធិ*** និង ***បច្ចេកវិទ្យាព័ត៌មាន*** នេះ ឧត្តមភាពប្រកួតប្រជែងរបស់ប្រជាជាតិមួយនៅតែអាស្រ័យជាសំខាន់លើកត្តាធនធានមនុស្ស ដែលមានចំណេះដឹង ចំណេះធ្វើទូលំទូលាយ មានភាពច្នៃប្រឌិត និងមានជំនាញច្បាស់លាស់ ។ ប្រការនេះតម្រូវឱ្យរាជរដ្ឋាភិបាលបន្តផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងៗទៅលើការអភិវឌ្ឍន៍ ***«មូលធនមនុស្ស»*** ដែលជាកត្តាមុតស្រួចក្នុងការជួយទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចកម្ពុជា ទាំងក្នុងពេលចំពោះមុខ ទាំងសម្រាប់អនាគត ជាពិសេសក្នុងពេលដែលកម្ពុជាមានចក្ខុវិស័យចង់ក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។

ឆ្លៀតឱកាសដ៏វិសេសវិសាលនេះ ខ្ញុំព្រះករុណាខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះចំពោះលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ មាតាបិតា អ្នកអាណាព្យាបាលសិស្ស អាជ្ញាធរដែនដី និងដៃគូអភិវឌ្ឍទាំងអស់ ដែលបានខិតខំប្រឹងប្រែងរួមចំណែកទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត ទាំងធនធានសម្រាប់ជួយជ្រោមជ្រែងដល់គ្រប់សកម្មភាព ដើម្បីបុព្វហេតុកសាង និងអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាឱ្យមានដំណើរការប្រកបដោយជោគជ័យក្នុងរយៈកាលកន្លងមកនេះ ។ ក្នុងនោះ លោកគ្រូអ្នកគ្រូបានខិតខំអស់ពីលទ្ធភាព ឈរលើមនសិការវិជ្ជាជីវៈប្រកបដោយសេចក្តីថ្លៃថ្នូរ មានគំនិតច្នៃប្រឌិត គោរពវិន័យ ស្របតាមក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ក្នុងការបំពេញការងារតាមតួនាទីភារកិច្ចរៀងៗខ្លួន ប្រកបដោយប្រសិទ្ធភាពក្នុងបុព្វហេតុកសាង និងអភិវឌ្ឍវិស័យអប់រំនៅគ្រប់ភូមិសិក្សាឱ្យដំណើរការប្រកបដោយជោគជ័យ ។ ជាមួយនេះ ក្រសួងអប់រំ យុវជន និងកីឡាបាន និងកំពុងអនុវត្តការកែទម្រង់ស៊ីជម្រៅសម្រាប់ការងារអប់រំ ជាអាទិ៍លទ្ធផលនៃការប្រឡងសញ្ញាបត្រទុតិយភូមិថ្មីៗ ដែលសិស្សទទួលបាននិទ្ទេស **A** រហូតដល់ ៤០៥ នាក់ នេះ គឺជាសារឆ្លើយតប និងបង្ហាញអំពីការចូលរួមជួយជ្រោមជ្រែងជំរុញឱ្យគុណភាពអប់រំមានភាពល្អប្រសើរនាពេលកន្លងមក និងពេលអនាគត ។

ក្នុងឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំក៏សូមសម្តែងនូវការអបអរសាទរ និងលើកទឹកចិត្តខ្ពស់ចំពោះក្មួយៗសិស្សានុសិស្សទាំងអស់ ទាំងសិស្សទើបនឹងចូលរៀនថ្មី ទាំងសិស្សចាស់នៅគ្រប់ភូមិសិក្សា ហើយខ្ញុំព្រះករុណាខ្ញុំសូមគាំទ្រជានិច្ចរិកចំពោះថ្ងៃបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០១៦-២០១៧ ដែលប្រារព្ធឡើងនៅទូទាំងប្រទេសស្របនឹងពេលដែលប្រទេសជាតិស្ថិតក្នុងសុខសន្តិភាព វឌ្ឍនភាព និងភាពសុខដុម ។

*- ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*- បងប្អូនជនរួមជាតិជាទីស្នេហា !*

ពេលកន្លងទៅ ក៏ដូចបច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡាដើរតួយ៉ាងសំខាន់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការកែទម្រង់វិស័យអប់រំ ការកសាងជំនឿទុកចិត្តចំពោះការងារអប់រំ ក៏ដូចជាគោល-នយោបាយរបស់រាជរដ្ឋាភិបាល ។ ក្នុងនោះ យើងបានប្តេជ្ញាហើយថា មិនទុកឱ្យកូនចៅយើងណាម្នាក់ស្ថិតនៅក្រៅ ឬ មិនបានទទួលសេវាអប់រំឡើយ ។ ទន្ទឹមនេះ ខ្ញុំព្រះករុណាខ្ញុំក៏សូមអំពាវនាវឱ្យជនរួមជាតិយើងទាំងអស់ចូរនាំគ្នាយកកូនចៅទៅចុះឈ្មោះចូលរៀន ក្នុងដើមបវេសនកាលឆ្នាំសិក្សាថ្មីនេះឱ្យបានគ្រប់ៗគ្នា និងចូលរួមតាមដានការសិក្សារបស់កូនចៅយើងថែមទៀត ក្នុងនោះអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវជួយសម្របសម្រួល និងផ្តល់លទ្ធភាពជូនដល់ពួកគេឱ្យបានចូលរៀន និងរៀនបានចប់តាមកម្រិតថ្នាក់ និងចប់ភូមិសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ឱ្យសមនឹងពាក្យថា **« ចំណេះវិជ្ជាជាទ្រព្យគាប់ប្រសើរ »** ។

ក្នុងស្មារតីនេះ យើងត្រូវបន្តចូលរួមទាំងអស់គ្នា ដើម្បីអភិវឌ្ឍវិស័យអប់រំរបស់យើងឱ្យកាន់តែរីកលូត-លាស់បន្ថែមទៀត ។ ជាក់ស្តែង រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តខ្ពស់ និងបន្តការខិតខំពុះពារដោះស្រាយរាល់ចំណុចសេសសល់ និងសំណូមពរនានា ក្នុងបុព្វហេតុលើកកម្ពស់វិស័យអប់រំ ទាំងអ្នកសិក្សា និងគ្រូបង្រៀនឱ្យប្រកបដោយគុណភាព និងប្រសិទ្ធភាព ស្របតាមនិន្នាការរីកចម្រើន និងបទដ្ឋានអប់រំ ទាំងក្នុងតំបន់ និងពិភព-លោក ។ ជាការពិត ដើម្បីអនុវត្តបាននូវស្មារតីនេះ ទាមទារឱ្យយើងប្រមែប្រមូលកម្លាំង និងធនធានសរុបពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីរួមគ្នាគាំទ្រលើកកម្ពស់វិស័យអប់រំជាតិ ដោយមិនមាននរណាម្នាក់នៅក្រៅសេវាអប់រំ និងត្រូវការបណ្តុះបណ្តាលឱ្យកូនចៅ ពិសេសយុវជនយើងជំនាន់ក្រោយឱ្យក្លាយជាមូលធនមនុស្សដែលមានសមត្ថភាព និងជំនាញខ្ពស់គ្រប់ៗគ្នា ប្រកបដោយសក្តានុពលសម្រាប់ពេលអនាគត ។

ក្នុងឱកាសបើកបវេសនកាលឆ្នាំសិក្សាថ្មីនេះ ខ្ញុំព្រះករុណាខ្ញុំសូមផ្តាំទៅក្មួយៗសិស្សានុសិស្ស និងយុវជនយុវនារីទាំងអស់ថា បើយើងស្រឡាញ់ខ្លួន ស្រឡាញ់ឪពុកម្តាយ និងស្រឡាញ់អនាគតដ៏រុងរឿង គឺនៅឱ្យឆ្ងាយពីគ្រឿងញៀន និងត្រូវចេះណែនាំចំពោះមិត្តភក្តិអំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន ។ ទន្ទឹមនោះ ចូរក្មួយៗប្រតិបត្តិច្បាប់ចរាចរណ៍ឱ្យបានខ្ជាប់ខ្ជួន ដោយត្រូវចេះយោគយល់ និងមានអធ្យាស្រ័យគ្នា ដើម្បីធានាបាននូវសុវត្ថិភាពផ្ទាល់ខ្លួនឯង និងអ្នកដទៃ ក៏ដូចជារក្សាបាននូវសេចក្តីថ្លៃថ្នូរដល់សង្គមជាតិយើងទាំងមូលផងដែរ ។

ជាមួយគ្នានេះ ខ្ញុំព្រះករុណាខ្ញុំស្នើសុំឱ្យមាតាបិតា ឬ អ្នកអាណាព្យាបាលសិស្ស សហគមន៍ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវរួមចំណែកឱ្យបានខ្លាំងក្លា ដើម្បីធានា និងរក្សាឱ្យបាននូវការអនុវត្តគោល-នយោបាយ ***«ភូមិ- ឃុំមានសុវត្ថិភាព»*** ហើយចូលរួមយ៉ាងសកម្មក្នុងការជួយអប់រំកូនចៅ ទាំងផ្នែកសុខភាព ចំណេះដឹង និងសីលធម៌ ដើម្បីបន្តលើកកម្ពស់កិត្តិយសសង្គមជាតិឱ្យស័ក្តិសមជាប្រជាជនដែលមានឈាមជ័រតភ្ជាប់គ្នាពីសម័យអង្គរដ៏រុងរឿងនៃយើង ។ ដោយឡែកដោយរដូវកាលនេះជារដូវកាលទឹកឡើង ដូច្នេះសូមបងប្អូនប្រជាជនត្រូវមានការប្រុងប្រយ័ត្នមើលថែទាំកូន ចៅឱ្យបានដិតដល់ ដើម្បីចៀសវាងការលង់ទឹក ឆ្លងជំងឺតម្កាត់ផ្សេងៗ ។ ខ្ញុំព្រះករុណាខ្ញុំក៏សូមអំពាវនាវផងដែរដល់ជនរួមជាតិទាំងអស់ សូមទៅចូលរួមចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ។

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណាខ្ញុំសូមថ្លែងអំណរព្រះគុណចំពោះព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ សូមអរគុណចំពោះបងប្អូនជនរួមជាតិ លោកគ្រូអ្នកគ្រូ បុគ្គលិកអប់រំ សាស្ត្រាចារ្យទាំងអស់នៅទូទាំងប្រទេស ព្រមទាំងដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងសប្បុរសជននានាដែលតែងតែបានរួមចំណែកកស្ថាបនា និងអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាឱ្យមានដំណើរការរីកចម្រើនគួរជាទីមោទនៈ ក្នុងរយៈកាលកន្លងមកនេះ និងសូមបន្តជួយឧបត្ថម្ភគាំទ្រ និងផ្តល់នូវកិច្ចសហការដ៏ល្អតទៅមុខទៀត ដើម្បីបុព្វហេតុនៃការអប់រំ ការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ។

នៅទីបញ្ចប់ ក្នុងឱកាសបើកបវេសនកាលឆ្នាំសិក្សា ២០១៦-២០១៧ ខ្ញុំព្រះករុណាខ្ញុំសូមប្រគេនពរព្រះតេជគុណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមជូនពរដល់បងប្អូនជនរួមជាតិ លោកគ្រូអ្នកគ្រូ បុគ្គលិកអប់រំ សាស្ត្រាចារ្យ ក្មួយៗសិស្សានុសិស្ស- និស្សិតទាំងអស់នៅទូទាំងប្រទេស សូមប្រកបដោយពុទ្ធពរទាំង ៤ ប្រការ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

***សូមអរព្រះគុណ និងអរគុណ !***

*រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**